# ឈ្មោះប្រាសាទ ប្រែរូប

ប្រាសាទប្រែរូបស្ថិតនៅផ្លូវវង់ធំ នៅតាមផ្លូវពីអង្គរវត្តឆ្ពោះទៅថ្នល់បារាយណ៍ (ឬហៅតាមបារាំងថា៖ បារាយណ៍ខាងកើត) និងភូមិប្រដាក ឬផ្លូវទៅបន្ទាយស្រី។ តួប៉មរបស់ប្រាសាទនេះសាងអំពីឥដ្ឋលើខឿនប្រាំថ្នាក់ធ្វើអំពីថ្មបាយក្រៀម។

ប្រាសាទប្រែរូបសាងនៅឆ្នាំ៩៦១ ដោយមន្ត្រីម្នាក់ដែលជាស្ថាបត្យករ ឈ្មោះ "**កវិន្ទ្រារិមថន** Kavindrārimathana" នៅក្នុងរាជ្យព្រះបាទ**រាជេន្ទ្រវរ្ម័ន** (គ.ស. ៩៤៤~៩៦៨)។ ស្ថាបត្យកររបស់ព្រះរាជារូបនេះ ក៏បានសាងប្រាសាទផ្សេងទៀតដែរ ដូចជាបាតជុំ (៩៥៣) និងមេបុណ្យ (ខាងកើត) ដែលសម្រាប់ឧទ្ទិសដល់បុព្វការីជនរបស់ព្រះរាជាជាដើម។ ថ្វីត្បិតព្រះរាជាគោរពព្រហ្មញ្ញសាសនាក្តី ប៉ុន្តែគាត់ជាអ្នកជឿគោរពព្រះពុទ្ធសាសនា ដូច្នោះហើយបានជាគាត់សាងប្រាសាទបាតជុំសម្រាប់ខ្លួនគាត់ ហើយឧទ្ទិសថ្វាយដល់ទេពព្រះពុទ្ធសាសនាធំៗបីអង្គ ពោលគឺព្រះពុទ្ធ **លោកេស្វរ** និង**ប្រាជ្ញាបារមី**។ នេះបញ្ជាក់ឲ្យឃើញថា គ្មានការរើសអើង ឬបិទសិទ្ធិសេរីភាពនៅក្នុងជំនឿសាសនានាសម័យបុរាណឡើយ។

ឈ្មោះនៃប្រាសាទនេះសព្វថ្ងៃ ដើមឡើយអាចមកពីឈ្មោះនៃប្រតិមាទេពមួយដែលមានចារនៅក្នុងសិលាចារឹក (K. 806) នៃប្រាសាទប្រែរូបនេះ គឺ "**វិស្វរូប** Viśvarūpa" ដែលឈ្មោះវែងសរសេរ "**រាជេន្ទ្រវិស្វរូប**"។ វាអាចជាការវិវត្តន៍នៃពេលវាលា ឬសម្លេងនៃការហៅ "**វិស្វរូប > វ្រះរូប > ព្រះរូប > ប្រេរូប**"។ មែនទែនទៅ បើស្តាប់អ្នកស្រុកដែលរស់នៅអង្គរ សម្លេងគាត់ហៅ "**ប្រេរូប**" មិនឮ "**ប្រែរូប**" ទេ។ ប្រាដកណាស់នៅអ្នករស់នៅខាងជើងអង្គរពេលនិយាយគ្មានខ្យល់ "ែ◌" គឺមានតែ "េ◌"។ ឧ. **ស្រែ > ស្រេ, ដឹង > ដេញ** ។ល។

ការដែលសរសេរ ឬហៅ "**ប្រែរូប**" នេះវាក្រោយមកទេ អាចថានៅពេលដែលបារាំងចូលមកអភិរក្សប្រាសាទអង្គរ។ គ្រាន់ជាងឈ្មោះនៃភូមិ "**ប្រដាក**" > "**ព្រះដាក់**" ដែលទើបបង្កើតជារឿងព្រេងឡើងនៅទសវត្ស១៩៨០ ដោយមិនដឹងឈ្មោះដើមនៃភូមិពិតប្រាដក។ ឈ្មោះប្រាសាទមួយចំនួនមិនថានៅអង្គរ ឬនៅតំបន់ផ្សេងៗទៀត វាជាការបង្កើតថ្មីភ្ជាប់នឹងរឿងព្រេង ហើយរឿងព្រេងភាគច្រើនបង្កើតឡើងនៅរវាងស.វទី១៩ និងដើមស.វទី២០។ រឿងព្រេងជាទូទៅគេបង្កើតឡើងភ្ជាប់ទៅនឹងប្រវត្តិសាស្ត្រខ្លះ ហើយធ្វើឲ្យទៅជារឿងដែល

អត្ថបទដោយ៖ **លោក ញឹម សុធារិទ្ធ**

មានភាពអស្ចារ្យ ឬអ្នកតែងចង់បង្ហាញអំពីភាពមិនច្បាស់លាស់ នៃទិដ្ឋភាពប្រវត្តិសាស្ត្រ ឬក៏ប្រៀបធៀបទៅនឹងសង្គមនាពេលមួយនោះ។

ឧទាហរណ៍រឿងតាត្រសក់ផ្អែមដែលប្រើលំពែងធ្វើឃាតស្ដេច ហើយឡើងគ្រងរាជ្យនៅស.វទី១៤។ នៅក្នុងប្រវត្តិសាស្ត្រពិត នៅពាក់កណ្ដាលស.វទី១៤ និងទី១៥ គឺមិនមានភាពច្បាស់លាស់ ដោយសារគ្មានឯកសារ គ្មានសិលាចារឹកណាមួយបញ្ជាក់ (ព្រះរាជពង្សាវតារមិនអាចយកជាមូលដ្ឋានបាន ទាំងពង្សាវតារខ្មែរ ទាំងសៀម និងលាវ)។ មែនទែនរឿងតាត្រសក់ផ្អែមនេះ មាននិយាយតាំងពីស.វទី១០ម៉្លេះនៅស្រុកភូមា គ្រាន់តែខាងភូមាតាប្រើពូថៅធ្វើឃាតស្ដេច រីឯខ្មែរឲ្យអស្ចារ្យបន្តិច គឺប្រើលំពែង)។ និយាយទាក់ទងនឹងការបង្កើតរឿងព្រេងនេះអាចវែងឆ្ងាយបន្តិច តែគ្រាន់ចង់បញ្ជាក់ថាមានរឿងព្រេងខ្មែរល្បីៗច្រើនគួរសមដែលចម្លងពីគេ ដូចជារឿងព្រះគោ ព្រះកែវ ដែលបង្កើតនៅស.វទី១៨ គឺចម្លងពីរឿងព្រះកែវទាក់ទងនឹងព្រឹត្តិការណ៍កើតឡើងនៅស្រុកលាវ ពេលដែលកងទ័ពសៀមចូលវាយនៅស.វទី១៧ ។ ល។

ឥឡូវនេះយើងមកពិចារណារឿងឈ្មោះ "ប្រាសាទប្រែរូប" វិញ ដូចដែលមានរូបថតបញ្ជាក់ស្រាប់នៅទីនេះ ឃើញមានសំណង់ថ្មភក់រាងបួនជ្រុងនៅពីមុខជណ្ដើរឡើងទៅប្រាង្គខាងលើ (រូបលេខ១) និងសំណង់តូចថ្មបាយក្រៀមនៅជ្រុងឦសាននៃប្រាសាទនេះ (រូបលេខ២)។ គេយកសំណង់ទាំងពីរនេះទៅភ្ជាប់នឹងរឿងតាត្រសក់ផ្អែម។ សំណង់ថ្មភក់រាងបួនជ្រុងនោះ (រូបលេខ៣) គេយល់ថាជាទីកន្លែងសម្រាប់បូជាសពរបស់ស្ដេចដែលតាត្រសក់ផ្អែមបានធ្វើឃាត។ នៅក្នុងទំនៀមនៃការបូជាសព យើងតែងតែប្រែសព (ឬជាកិច្ចប្រែសព ឬប្រែរូប) នៅពេលបូជា ពោលគឺដើម្បីឲ្យអ្នកដែលស្លាប់ទៅនោះបានទៅចាប់ជាតិថ្មី។ ដូច្នេះហើយបានជាគេហៅប្រាសាទនេះ ទៅជា "**ប្រែរូប**"។ រីឯសំណង់តូចថ្មបាយក្រៀមនោះ (រូបលេខ៤) គេយល់ថាជាកន្លែងសម្រាប់លាងធាតុបន្ទាប់ពីបូជាហើយ។

តាមពិតសំណង់ថ្មភក់រាងបួនជ្រុង ពោលគឺជាជើងទម្រសម្រាប់តម្កល់ព្រះគោ (ភាសាសំស្ក្រឹតហៅ **នន្ទិន** = Nandin) ដែលជាយានជំនិះរបស់ព្រះឥសូរ (ប្រាសាទឧទ្ទិសដល់ព្រះឥសូរភាគច្រើនតែងតែមានរបៀបនេះដាក់នៅខាងកើតប្រាង្គ ហើយប្រតិមាព្រះគោបែរចំទៅប្រាង្គ)។ រីឯសំណង់តូចថ្មបាយក្រៀមវិញ ខ្ញុំមិនដឹងអំពីតួនាទីរបស់វាក្នុងស្ថាបត្យកម្ម

ឬជំនឿឡើយ ដោយសារគ្មានឯកសារណាមួយបញ្ជាក់ច្បាស់។ ខ្លះថាជាទីកន្លែងតម្កល់សិលាចារឹករបស់ប្រាសាទនេះផ្ទាល់ ខ្លះថាតួនាទីវាទាក់ទងនឹងប្រព័ន្ធបង្ហូរទឹក?



រូបទលេខ១



រូបលេខ២



រូបលេខ៣



រូបលេខ៤

អត្ថបទដោយ៖ **លោក ញឹម សុធារិទ្ធ**